ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៦៣ ......សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការសម្របសម្រួលគម្រោងសាងសង់ស្ពាន និងផ្លូវល្បឿនលឿន ក្រោមទម្រង់វិនិយោគ សាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT) របស់វិទ្យាស្ថានរចនាសិក្សាស្រាវជ្រាវគម្រោងប្លង់គមនាគមន៍ខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១:** បង្កើតគណៈកម្មការសម្របសម្រួល និងសិក្សាគម្រោងផ្លូវល្បឿនលឿន និងស្ពាន ក្រោមទម្រង់វិនិយោគ BOT របស់វិទ្យាស្ថានរចនាសិក្សាស្រាវជ្រាវគម្រោងប្លង់គមនាគមន៍ ខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១. | លោក | **ប៉ែន ធីរុទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា (អថ) កសហវ | ប្រធាន |
| ២. | លោក | **ស៊ីង សុគង់** | អគ្គនាយករងផែនការរដ្ឋបាល កសកជ | អនុប្រធាន |
| ៣. | ឯកឧត្តម | **អៀង អូនធី** | អភិបាលរងរាជធានីភ្នំពេញ សាលារាជធានីភ្នំពេញ | សមាជិក |
| ៤. | លោក | **ម៉ឺន បុណ្ណារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ៥. | លោក | **ង៉ាវ សុផល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ៦. | លោក | **ស៊ិន បុណ្ណិមី** | នាយកទីចាត់ការរៀបចំក្រុង សាលារាជធានីភ្នំពេញ | សមាជិក |
| ៧. | លោក | **រស់ បរម** | ប្រធាននាយកដ្ឋានវិនិយោគ (នវ) នៃអថ កសហវ | សមាជិក |
| ៨. | លោក | **ឈួន សំរីទ្ធិ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃអថ កសហវ | សមាជិក |
| ៩. | លោក | **ឃុន ហេង** | ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត នៃគណៈកម្មការវិនិយោគកម្ពុជា កអក | សមាជិក |
| ១០. | លោក | **មឿង វិសុទ្ធ** | ប្រធាននាយកដ្ឋានស្តីទីនាយកដ្ឋានត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ កអក | សមាជិក |
| ១១. | លោក | **យ៉េន សុភ័ណ** | អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋាន កសហវ | សមាជិក |
| ១២. | លោក | **ឃុន សុខា** | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស កសកជ | សមាជិក |
| ១៣. | លោក | **ហ៊ូ គុណវឌ្ឍន៍** | អនុប្រធាននាយកដ្ឋានវិនិយោគ នៃអថ កសហវ | សហជិក |
| ១៤. | លោក | **ដារី ចេតនា** | អនុប្រធាននាយកដ្ឋានវិនិយោគ នៃអថ កសហវ | សមាជិក |
| ១៥. | លោក | **ហេង ណារិទ្ធ** | អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ១៦. | លោក | **ម៉ាង សុតារ៉ា** | ប្រធានការិយាល័យគ្រប់គ្រងបំណុល រដ្ឋបាល និងសរុប នាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃអថ កសហវ | សមាជិក |
| ១៧. | លោក | **ខិម ម៉ាក់ឆារិទ្ធ** | ប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នវ នៃអថ កសហវ | សមាជិក |
| ១៨. | លោក | **ញ៉ាន ទណ្ឌៈ** | ប្រធានការិយាល័យដោះស្រាយផលប៉ះពាល់ទី១ នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋាន កសហវ | សមាជិក |
| ១៩. | លោក | **នង គុន្ធារ៉ា** | ប្រធានការិយាល័យមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ កសកជ | សមាជិក |

| | | | |
|---|---|---|---|
| ២០. លោក | **ហេង ជំនិត** | អនុប្រធានការិយាល័យសវនកម្មទី៤ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ២១. លោក | **ស ប៊ុនរ៉េង** | អនុប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នវ នៃអថ កសហវ | សមាជិក |
| ២២. លោក | **លុយ សុក្រិត** | អនុប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នវ នៃអថ កសហវ | លេខា |

**ប្រការ ២:** គណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យ និងផ្តល់យោបល់ អំពីនីតិវិធី ក្របខ័ណ្ឌគតិយុត្ត បទដ្ឋានបច្ចេកទេស ព្រមទាំងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃគម្រោង
- សិក្សា និងផ្តល់យោបល់ អំពីហានិភ័យពាក់ព័ន្ធនានា នៃគម្រោង រួមទាំងផលប៉ះពាល់ខាងបរិស្ថាន និងសង្គម
- រៀបចំរបាយការណ៍ ស្តីពីលទ្ធផលការងារ។

**ប្រការ ៣:** ប្រធានគណៈកម្មការ អាចអញ្ជើញសមាជិកចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ ៤:** អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន សាលារាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ